# សារជូនពររបស់លោកអភិបាល អូលីវីយេ
# ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ
# ចំការទៀង ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០

សួស្តីឆ្នាំថ្មី
បងប្អូនជាទីស្រឡាញ់!

ខ្ញុំសូមជូនពរដល់បងប្អូនទាំងអស់ សម្រាប់ឆ្នាំថ្មីដែលបានចូលមកដល់ ឆ្នាំនេះជាឆ្នាំប្លែក ដោយសារយើងដឹងថានៅក្នុងពិភពលោកទាំងមូល មានបួនពាន់លាននាក់ដែលជាប់នៅក្នុងផ្ទះ ជាប់នៅក្នុងប្រទេសផ្ទាល់ខ្លួន។ យើងដឹងថាជំងឺកូវីដ១៩ កំពុងសម្លាប់មនុស្សយ៉ាងច្រើន សម្រាប់យើងនៅប្រទេសកម្ពុជាក៏មិនបានឈប់សម្រាកក្នុងថ្ងៃចូលឆ្នាំថ្មី មិនមានឱកាសដើម្បីចូលព្រះវិហារអធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់ប្រទានពរដល់គ្រួសារយើងសម្រាប់ចូលឆ្នាំថ្មីនេះ។ ក៏ប៉ុន្តែតាមផ្ទះតាមគ្រួសាររៀងៗខ្លួន យើងនឹងអធិដ្ឋានដើម្បីឲ្យព្រះជាម្ចាស់ប្រទានពរ។

ថ្ងៃនេះ ខ្ញុំជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខ្ញុំមានអំណរសប្បាយជួបជាមួយបងប្អូន និងសូមទូលអង្វរទៅព្រះជាម្ចាស់សូមព្រះអង្គប្រទានពរ ដើម្បីឲ្យគ្រួសារនីមួយៗមានសេចក្តីសុខ មានកម្លាំងកាយកម្លាំងចិត្ត មានសុខភាពល្អ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**អ្នកណាសោកសៅអ្នកនោះមានសុភមង្គលហើយ អ្នកណាត្រូវគេបៀតបៀនអ្នកនោះមានសុភមង្គលហើយ**" យើងឃើញនៅក្នុងបរិយាកាសនៃពិភពលោកសព្វថ្ងៃ យើងមានទុក្ខសោកយ៉ាងច្រើន ដោយសារមានមនុស្សស្លាប់ មានមនុស្សភ័យខ្លាច យើងមានការបៀតបៀនដោយជំងឺកូវីដ១៩។ ដូច្នេះ យើងដឹងថាយើងត្រូវតែតស៊ូដើម្បីឆ្លងឧបសគ្គនៃជំងឺកូវីដ១៩ និងដើម្បីទៅមុខទៀត ព្រះយេស៊ូក៏មានព្រះបន្ទូលទៀតថា "**អ្នកណាកសាងសុខសន្តិភាពអ្នកនោះមានសុភមង្គលហើយ អ្នកណាមានចិត្តមេត្តាករុណាអ្នកនោះមានសុភមង្គលហើយ**"។ ពិតមែន នៅបច្ចុប្បន្ននេះយើងទាំងអស់គ្នាដែលជាគ្រីស្តបរិស័ទ ឲ្យយើងយកចិត្តទុកដាក់កសាងសុខសន្តិភាពនៅក្នុងគ្រួសារយើង នៅក្នុងប្រទេសយើង ដោយមានចិត្តមេត្តាករុណា។ ជាពិសេស សម្រាប់បងប្អូនដែលចាប់ផ្តើមទទួលឥទ្ធិពលអាក្រក់ដោយសារជំងឺកូវីដ១៩ ឲ្យគេដឹងថាយើងជាព្រះសហគមន៍កាតូលិក យើងជាគ្រីស្តបរិស័ទ យើងជាគ្រួសារមួយដែលចេះលើកទឹកចិត្ត ដែលចេះធ្វើដំណើរជាមួយបងប្អូនទាំងអស់ ជាពិសេសជាមួយបងប្អូនតូចតាចដែលកំពុងបាត់បង់ទីពឹងទាំងអស់។

នៅក្នុងឆ្នាំថ្មីនេះ ខ្ញុំសូមជូនពរឲ្យបងប្អូនទាំងអស់ទទួលជីវិតថ្មីតាមរយៈព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ តាមរយៈព្រះនាងម៉ារីដែលជាមាតារបស់យើង ដែលព្រះយេស៊ូប្រទានឲ្យដើម្បីការពារថែរក្សាយើង។ ដូច្នេះ សម្រាប់ឆ្នាំនេះយើងបានចាប់ផ្តើមនៅក្នុងពេលវេលាដ៏ពិបាក ប៉ុន្តែដោយយើងជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម យើងបន្តធ្វើដំណើររួមជាមួយគ្នា បន្តតស៊ូរួមជាមួយគ្នា បន្តចូលរួមនៅក្នុងគ្រប់ការដឹកនាំពីរដ្ឋាភិបាលប្រទេសកម្ពុជា ដើម្បីរួមគ្នាយើងប្រឆាំងជំងឺកូវីដ១៩ យើងដើរឆ្ពោះទៅរកសេចក្តីសង្ឃឹមជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

ខ្ញុំសូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់
សូមព្រះម្ចាស់គង់នៅជាមួយបងប្អូន
សូមព្រះដ៏មានតេជានុភាពសព្វប្រការគឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធប្រទានព្រះពរ
ឲ្យអស់បងប្អូន
សូមអស់បងប្អូនមានសេចក្តីសុខ មានកម្លាំងកាយកម្លាំងចិត្ត
ជូនពរឆ្នាំថ្មី
អាលេលូយ៉ា អាលេលូយ៉ា